សូមជម្រាបសួរ! នេះជាការនិយាយអំពីរដូវនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងប្រទេសកម្ពុជាគឺ
ជាប្រទេសមួយដែលស្ថិតនៅក្នុងអាស៊ីអាគ្នេយ៍
ប្រទេសអាស៊ីអាគ្នេយ៍ហើយមានអាកាសធាតុក្ដៅហើយសើម
អញ្ចឹងគឺមានអាកាសធាតុក្ដៅហើយសើម គឺមានសំណើម។
ហើយរដូវនៅក្នុងប្រទេសកម្ពុជាគឺមានតែពីរនោះទេ វាខុសអំពីប្រទេសផ្សេងទៀត
ដូចប្រទេសលោកខាងលិចគឺ រដូវមានដល់ទៅបួន តែនៅក្នុងប្រទេសកម្ពុជាគឺ
ការបែងចែករដូវគឺមានតែពីរទេ គឺ គេហៅថារដូវប្រាំង ហើយនិងរដូវវស្សា។ ពាក្យថារដូវប្រាំង
គឺសំដៅទៅលើរដូវដែល រដូវក្ដៅ រដូវដែលអត់មានភ្លៀងធ្លាក់ អញ្ចឹងគឺជារដូវមួយដែលក្ដៅ
អញ្ចឹងយើងហៅថារដូវប្រាំង។ ហើយរដូវវស្សា គឺជារដូវមួយដែលមានភ្លៀងធ្លាក់ច្រើន
អញ្ចឹងយើងហៅថារដូវវស្សា។ ហើយជាទូទៅអាកាសធាតុគឺខុសគ្នាតែបន្តិចបន្តួចទេ គឺ
រដូវប្រាំងគឺក្ដៅ រដូវវស្សាក៏មិនជាត្រជាក់ខ្លាំងណាស់ណាដែរ គ្រាន់តែវាត្រជាក់ជាងរដូវប្រាំងបន្តិច
អញ្ចឹងត្រជាក់ដោយសារវាមានភ្លៀងច្រើន អញ្ចឹងធ្វើអាកាសធាតុ [...] ត្រជាក់ [...]
ប៉ុន្តែមិនត្រជាក់ដូចជានៅក្នុងប្រទេសលោកខាងលិចនោះទេ
ដូចជារដូវរងានៅក្នុងប្រទេសលោកខាងលិច គឺត្រជាក់ខ្លាំង តែនៅក្នុងប្រទេសកម្ពុជាវិញ គឺរដូវវស្សា
គឺ[ផ្ដោត?]សំខាន់ទៅលើមានភ្លៀងធ្លាក់ច្រើន
ហើយអាកាសធាតុគឺត្រជាក់ជាងរដូវក្ដៅតែបន្តិចតែប៉ុណ្ណោះ។ ហើយនៅក្នុងប្រទេសកម្ពុជា
គឺអាកាសធាតុ គឺក្ដៅហើយសើម មានន័យថាមិនមែនក្ដៅហើយស្ងួតនោះទេ ក្ដៅតែមានសំណើម
ហើយដូចជាធ្វើឲ្យយើងងាយនឹងបែកញើស។ អញ្ចឹងគឺពេលដែលក្ដៅ គឺយើងបែកញើសច្រើន។
អញ្ចឹងអាកាសធាតុក្ដៅហើយសើម ហើយរដូវសំខាន់ក៏មានតែពីរដែរ គឺរដូវប្រាំងនិងរដូវវស្សា។
ហើយរដូវទាំងពីរនេះ គឺ សំខាន់ដូចគ្នា គឺ មានន័យថា រដូវទាំងពីរ
សម្រាប់កសិករនៅក្នុងប្រទេសកម្ពុជា គឺរដូវវស្សា គឺសំខាន់ណាស់ ដូចជា [...] គឺការដាំ ធ្វើចំការ
ដាំស្រូវ ដូចជាការដាំស្រូវអីហ្នឹងគឺពឹងផ្អែកទៅលើទឹកភ្លៀង។ អញ្ចឹង[...] នៅក្នុងប្រទេសកម្ពុជា
ការធ្វើកសិកម្ម ការធ្វើចំការ ដាំដំណាំ អញ្ចឹងគឺកសិករ ពាក្យថាកសិករ គឺអ្នកធ្វើចំការ
អ្នកដាំដំណាំផ្សេងៗ [...] ប្រកបមុខរបរដែលធ្វើចំការគឺយើងហៅថា កសិករ។
អញ្ចឹងកសិករនៅក្នុងប្រទេសកម្ពុជាគឺ ពឹងផ្អែក ពឹងផ្អែកទៅលើទឹកភ្លៀង ដោយសារយើងអត់មានទឹក
ប្រព័ន្ធធារាសាស្ត្រ គ្រប់គ្រាន់នោះទេគឺកសិករពឹងផ្អែកសំខាន់ទៅលើទឹកភ្លៀង។ អញ្ចឹងគឺរដូវវស្សា
គឺសំខាន់សម្រាប់កសិករនៅក្នុងប្រទេសកម្ពុជា។ អញ្ចឹងដូចជានៅតាមជនបទគឺ អ្នកស្រែចំការ
អ្នកដាំដំណាំ កសិករហ្នឹង គឺគាត់រំពឹងទៅលើទឹកភ្លៀង។ អញ្ចឹងរដូវវស្សា
គឺជារដូវមួយដែលកសិករគាត់ ចាប់ផ្ដើមដាំដំណាំ គឺគាត់ចាប់រៀបចំដី រៀបចំចំការរបស់គាត់
ត្រៀមចាំទឹកភ្លៀង។ អញ្ចឹងគឺកសិករនៅក្នុងប្រទេសកម្ពុជា គឺគាត់ដឹងពីពេលវេលា ថាតើនៅខែណា
នៅពេលណាដែលនឹងមានភ្លៀងធ្លាក់ ហើយក៏ជាពេលវេលាមួយដែលគាត់នឹងដាំដំណាំដែរ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគឺរដូវវស្សា គឺជារដូវដែលសំខាន់ណាស់សម្រាប់កសិករនៅក្នុងប្រទេសកម្ពុជា
ហើយក៏ជារដូវមួយដែលមានតួនាទីសំខាន់ដែរ គឺផ្ដល់ទឹកភ្លៀង ផ្ដល់ទឹកសម្រាប់កសិករ
ដោយសារបើសិនជាគ្មានភ្លៀងទេ គឺកសិករមិនអាចដាំដំណាំបាននោះទេ។
ហើយកសិករគឺពឹងផ្អែកទៅលើទឹកភ្លៀងទាំងស្រុងតែម្ដងក្នុងការដែលធ្វើចំការ
ក្នុងការដែលដាំដំណាំ។ ហើយនៅក្នុងរដូវវស្សា បើយើងក្រឡេកមើលទៅ គឺយើងឃើញថាគឺមានរដូវ
គឺជារដូវមួយដែលគេមានប្រារព្ធពិធីបុណ្យដែរ
ដោយសារនៅក្នុងប្រទេសកម្ពុជាគឺមានប្រារព្ធពិធីបុណ្យជាច្រើន ហើយនៅក្នុងរដូវវស្សា
ពិធីបុណ្យដែលសំខាន់នោះគឺ យើងហៅថា ពិធីបុណ្យអុំទូក។ អញ្ចឹងយើងហៅថាពិធីបុណ្យអុំទូក
ដែលពិធីបុណ្យអុំទូកគឺធ្វើនៅក្នុងរដូវវស្សា គឺក្នុងរដូវពេលទឹកឡើង ដូចជាទឹកទន្លេ
ទឹកទន្លេមេគង្គឡើងខ្លាំង ហើយយើងហៅថាពិធីបុណ្យអុំទូក។
ពិធីបុណ្យអុំទូកគឺជាពិធីបុណ្យមួយដែលប្រារព្ធធ្វើពេលដែលមានការប្រកួតប្រណាំងអុំទូក
ដូចជាយើងមានទូកចែវ ឬក៏ទូកអុំហ្នឹង គឺយើងប្រណាំងគ្នា គឺអ្នកដែលមកពីខេត្តផ្សេងៗហ្នឹង
គឺទៅប្រកួតប្រណាំងនៅទីក្រុង នៅក្នុងទីក្រុងភ្នំពេញ។ អញ្ចឹងយើងហៅថាពិធីបុណ្យអុំទូក។
ហើយជា[…] ពេលវេលាមួយដែលមានផ្ដល់ឱកាសដល់អ្នកផ្សេងៗ
អ្នករស់នៅក្នុងប្រទេសកម្ពុជា[…]ការសម្រាកហើយលំហែ ហើយចូល[…]ពិធីបុណ្យនេះផងដែរ
ដូចជាអ្នកនៅតាមទីជនបទ តាមខេត្តគឺគាត់ឡើងមកទីក្រុងដើម្បីមើលពិធីបុណ្យអុំទូកនេះ
អញ្ចឹងគឺមានភាពកុះករខ្លាំងណាស់ នៅក្នុងទីក្រុង
ពីព្រោះមានមនុស្សម្នាជាច្រើនមកមើលពិធីបុណ្យអុំទូក។
ហើយបន្ទាប់មកទៀតគឺយើងអាចនិយាយអំពីរដូវប្រាំង។
ចំណែករដូវប្រាំងវិញគឺជារដូវមួយដែលមិនមានភ្លៀងធ្លាក់ច្រើនទេគឺ ចាប់ពីខែ ដូចជាខែដប់ពីរ […]
ខែធ្នូ រហូតទៅដល់ខែបួនយើងហៅថាខែមេសា អញ្ចឹងចាប់ពីខែធ្នូរហូតដល់ខែមេសា គឺរដូវប្រាំង
ហើយរដូវវស្សាគឺចាប់ពីខែ ប្រាំរហូតទៅដល់ខែដប់មួយ។ អញ្ចឹងខែប្រាំ គឺខែ ឧសភា
រហូតទៅដល់ខែ ខែដប់មួយអញ្ចឹងគឺ ខែវិច្ឆិកា អញ្ចឹងគឺរដូវវស្សា គឺចាប់ពីខែ មេសា
រហូតដល់ខែវិច្ឆិកា ចំណែករដូវប្រាំងវិញគឺចាប់ពីខែ ធ្នូ រហូតទៅដល់ខែមេសា អញ្ចឹងខែដប់ពីរ
រហូតដល់ខែបួន។ ហើយនៅក្នុងរដូវប្រាំង គឺបើសិនជាអាកាសធាតុវិញ[?]គឺក្ដៅ
ហើយបើសិនជាអ្នកដែលនៅតាមជនបទវិញគឺ ដីហុយខ្លាំងមែនទែន ដោយសារផ្លូវអត់ល្អ។
អញ្ចឹងគឺអ្នកដែលរស់នៅតាមជនបទគឺ តែងតែប៉ះពាល់រហូតដោយសារផ្លូវ និងប្រព័ន្ធគមនាគមន៍
ប្រព័ន្ធធ្វើដំណើរផ្លូវថ្នល់ហ្នឹង គឺអត់ល្អនៅតាមជនបទ រដូវប្រាំងគឺតែងតែដីហុយច្រើន
ហើយចំណែករដូវវស្សាវិញ គឺភក់ ពីបង្ការធ្វើដំណើរ ភក់ ហើយរដូវប្រាំងគឺដីហុយ
ក៏មិនងាយស្រួលប៉ុន្មានដែរ គ្រាន់តែថាយើងអាចធ្វើដំណើរទៅបាន តែគឺមានដី ដីហុយយ៉ាងច្រើន។
ហើយរដូវប្រាំងគឺជារដូវមួយដែលមានការសម្រាក ដូចជាក៏មិនមានញ្ញើក?]អំពីការប្រមូលផល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់ពីការប្រមូលផលគឺកសិករអាចមានការសម្រាកបាន ហើយ ជាទូទៅគឺ
យើងមានតាមទំនៀមទម្លាប់ យើងហៅថាពិធីបុណ្យចូលឆ្នាំខ្មែរ គឺធ្វើនៅខែមេសា
អញ្ចឹងគឺជាខែនៅក្នុងរដូវប្រាំងនេះដែរ
ហើយមូលហេតុដែលយើងធ្វើពិធីបុណ្យចូលឆ្នាំខ្មែរនៅក្នុងខែមេសា ដោយសារជាខែមួយដែល
កសិករបញ្ចប់ការប្រមូលផល អញ្ចឹងគឺប្រមូលផលពីដំណាំ ចំការរួច គឺ គឺគាត់មានការប្រារព្ធពិធី
គឺចូលឆ្នាំថ្មី អញ្ចឹងគឺមានការលំហែ ការសម្រាក ការលេងល្បែងប្រជាប្រិយផ្សេងៗ
អញ្ចឹងយើងហៅថាពិធីបុណ្យចូលឆ្នាំខ្មែរ ដែលជារៀងរាល់ឆ្នាំគឺប្រារព្ធនៅក្នុងខែមេសា
ដែលជាខែមួយដែលកសិករបានប្រមូលផល ហើយមានការសប្បាយរីករាយអបអរសាទរចូលឆ្នាំថ្មី។
អញ្ចឹងនៅក្នុងខែមេសនេះ[...] ពិធីបុណ្យចូលឆ្នាំខ្មែរ។
ហើយសរុបសេចក្ដីមកនៅក្នុងប្រទេសកម្ពុជា គឺមានរដូវពីរ គឺរដូវប្រាំង និងរដូវវស្សា។
ហើយពិធីបុណ្យនៅក្នុងរដូវវស្សា គឺពិធីបុណ្យអុំទូក ដោយសារមានទឹកឡើងខ្លាំង
ហើយពិធីបុណ្យនៅក្នុងរដូវប្រាំង គឺពិធីបុណ្យចូលឆ្នាំខ្មែរ បន្ទាប់ពីមានការប្រមូលផលដំណាំ
កសិករមានការសប្បាយរីករាយ និងការប្រមូលផល ហើយរីករាយ[ក្នុង ?]ការដែលចូលឆ្នាំថ្មី។
អញ្ចឹងពិធីបុណ្យចូលឆ្នាំថ្មីគឺ ធ្វើនៅក្នុងខែមេសា ដែលជារដូវប្រាំង បន្ទាប់ពីការប្រមូលផលដំណាំរួច។
ហើយខ្ញុំក៏សូមបញ្ចប់ការពិពណ៌នាទៅលើរដូវទាំងពីរ
ហើយនឹងពិធីបុណ្យនៅក្នុងប្រទេសកម្ពុជានេះដោយប៉ុណ្ណេះដែរ។ សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.